**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**

លេខ ...៣០៣......បទ.អ.រ.ល............

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០១៧

**គោរពជូន**

- **ឯកឧត្តម អគ្គាធិការ នៃអគ្គាធិការដ្ឋាន**
- **ឯកឧត្តម អគ្គនាយករដ្ឋបាល**
- **ឯកឧត្តម អគ្គនាយក ប្រៃសណីយ៍ និងទូរគមនាគមន៍**
- **ឯកឧត្តម អគ្គនាយក បច្ចេកវិទ្យា គមនាគមន៍ និង ព័ត៌មាន**
- **ឯកឧត្តម ប្រធានវិទ្យាស្ថានជាតិប្រៃសណីយ៍ និងទូរគមនាគមន៍ បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន**
- **ឯកឧត្តម ប្រធាននិយ័តករទូរគមនាគមន៍កម្ពុជា**
- **ឯកឧត្តម ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយកប្រៃសណីយ៍កម្ពុជា**
- **ឯកឧត្តម ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយកទូរគមនាគមន៍កម្ពុជា**
- **លោកប្រធាននាយកដ្ឋាន សវនកម្មផ្ទៃក្នុង**

**កម្មវត្ថុ** : សំណើសុំចាត់តាំងមន្ត្រីរាជការដែលមានអាយុចាប់ពី២២-៣៩ឆ្នាំ ចូលរួមសិក្ខាសាលាផ្សព្វផ្សាយអាហារូបករណ៍ Japan Development Scholarship(JDS) ឆ្នាំ២០១៧ នៅក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

**យោង** : -លិខិតចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ២០១៧ របស់អង្គការ JICE។
-ចំណាររបស់ឯកឧត្តមរដ្ឋមន្ត្រី ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមគោរពជូន **ឯកឧត្តម និងលោក លោកស្រីប្រធានអង្គភាព** ក្រោមឱវាទរបស់ក្រសួងប.ទទាំងអស់មេត្តាជ្រាបថា ដោយមានការសហការជាមួយមជ្ឈមណ្ឌលសហប្រតិបត្តិការអន្តរជាតិជប៉ុន(JICE) ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ នឹងធ្វើការរៀបចំសិក្ខាសាលាផ្សព្វផ្សាយអាហារូបករណ៍របស់ Japan Development Scholarship(JDS-2017) ដែលនឹងប្រព្រឹត្តទៅនៅ**ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៧ វេលាម៉ោង ០៩:០០ នាទីព្រឹក** នាសាលប្រជុំធំ ទីស្តីការក្រសួងប.ទ ដើម្បីផ្សព្វផ្សាយជូនមន្ត្រីរាជការក្រសួងប.ទ ដែលមានគោលបំណងចង់បន្តការសិក្សា និងចំណេះដឹងបន្ថែម ព្រមទាំងបទបង្ហាញស្តីពីនីតិវិធីក្នុងការរៀបចំបែបបទសម្រាប់ដាក់ពាក្យស្នើសុំអាហារូបករណ៍ខាងលើ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម និងលោក លោកស្រីប្រធានអង្គភាព** ក្រោមឱវាទក្រសួងប.ទ មេត្តាជ្រាប និងចាត់តាំងមន្ត្រីដែលមានអាយុចាប់ពី២២-៣៩ឆ្នាំ និងមានបំណងចង់បន្តការសិក្សា ឲ្យចូលរួមក្នុងកម្មវិធីផ្សព្វផ្សាយខាងលើដោយផ្ញើឈ្មោះមក នាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាល ឲ្យ**បានត្រឹមថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៧** ដើម្បីឲ្យនាយកដ្ឋានមានពេលវេលាគ្រប់គ្រាន់ដើម្បីរៀបចំ។

សូម **ឯកឧត្តម និងលោក លោកស្រីប្រធាន អង្គភាព** ទទួលនូវការគោរពរាប់អានអំពីខ្ញុំ។

**អគ្គនាយករដ្ឋបាល**

**លីវ គីមហេង**

**បញ្ជាក់៖** សម្រាប់ព័ត៌មានលម្អិត:
-ទំនាក់ទំនងការិយាល័យបណ្តុះបណ្តាល ទូរស័ព្ទលេខ៖
០១២ ៩៧៩ ០៧៩ ឬ ០៩៦ ៧០០ ៦៦៦៦

កាច់ជ្រុងវិថីលេខ១១៣និង១០២សង្កាត់វត្តភ្នំខណ្ឌដូនពេញ
ទូរស័ព្ទ (៨៥៥) ២៣-៧២៤៨០៩/៤២៨២៤៦
ទូរសារ (៨៥៥) ២៣-៤២៦៥៤១/៤២៦០០៥/៧២៤៨០៩